សហគមន៍ខ្មែរកម្ពុជាក្រោម
KHMER KAMPUCHEA KROM COMMUNITY
LA COMMUNAUTÉ DU KHMER KAMPUCHEA KROM

លេខ..............................ស.ខ.ក.ក.

# សេចក្តីប្រកាសព័ត៌មាន

អង្គការ-សមាគមខ្មែរកម្ពុជាក្រោម សូមជំរាបជូនដំណឹងដល់ទីភ្នាក់ងារសារព័ត៌មានជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ មេត្តាជ្រាបថា អង្គការ-សមាគមខ្មែរកម្ពុជាក្រោម បានរៀបចំធ្វើបុណ្យរាប់បាត្រព្រះសង្ឃចំនួន១៩៤៩អង្គ ដើម្បីឧទ្ទិសកុសលប្រគេន ថ្វាយ និងជូន ព្រះវិញ្ញាណក្ខន្ធព្រះវីរសមណៈ ព្រះវិញ្ញាណក្ខន្ធព្រះវីរព្រះមហាក្សត្រ និងវិញ្ញាណក្ខន្ធវីរបុរស វីរនារី វីរយុទ្ធជន យុទ្ធនារីខ្មែរស្នេហាជាតិទាំងអស់ ដែលបានបូជាព្រះកាយនិងបូជាកាយក្នុងបុព្វជាតិមាតុភូមិខ្មែរ និងប្រារព្ធទិវាកាន់ទុក្ខជាតិខ្មែរនៅថ្ងៃទី០៤ ខែមិថុនា នៃថ្ងៃអាណានិមបារាំងកាត់ទឹកដីខ្មែរឲ្យអាណានិគមវៀតណាម ជារៀងរាល់ឆ្នាំ។ ឆ្នាំនេះ ត្រូវបានអាជ្ញាធររាជធានីភ្នំពេញពុំបានអនុញ្ញាតទីកន្លែងសំរាប់ប្រារព្ធពិធីនេះទេ ទោះនៅថ្ងៃទី០៤ ខែមិថុនា ឬលើកពេលទៅថ្ងៃទី១០ខែមិថុនាឆ្នាំ២០១២ក្តី។

ដោយសារបញ្ហាទីកន្លែងនៅទីសាធារណៈ និងតាមវត្តអារាម មិនអាចធ្វើបាន អង្គការ-សមាគមខ្មែរកម្ពុជាក្រោម បានសំរេចលើកពេលសារជាថ្មីម្តងទៀត គឺនិងធ្វើនៅថ្ងៃអាទិត្យទី១៧ ខែមិថុនាឆ្នាំ២០១២នៅគេហដ្ឋានឯកឧត្តមគង់ គាំ ផ្ទះលេខ៧១ មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

ភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២
លេខាធិការដ្ឋាន

ទីស្នាក់ការបណ្តោះអាសន្នផ្ទះលេខៈ ១០B ផ្លូវលេខ២៣៤ សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទលេខៈ (៨៥៥) ១២ ៩០៨ ៨៨២ / ០៩០ ៤៧៧ ០០៧
E-mail: thachsetha@gmail.com, Website: www.khmerkromngo.org